# កម្លាំងពលកម្ម និងការរីកចម្រើននៃបច្ចេកវិទ្យា

នៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្ម៤.០ បច្ចេកវិទ្យាកាន់តែមានការរីកចម្រើនខ្លាំងឡើង ហើយបានជ្រៀតចូលទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសវត្តមាននៃការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងការបំពេញការងារ កាន់តែមានភាពទូលំទូលាយជាងមុន ស្របពេលដែលបច្ចេកវិទ្យាទាំងនោះកាន់តែមានភាពវៃឆ្លាត ដោយអាចចូលរួមជួយដោះស្រាយបញ្ហាមនុស្សបានកាន់តែប្រសើរជាងមុន។ ជាមួយគ្នានេះ មានការលើកឡើងពីបញ្ហាប្រឈមនៃការបាត់បង់តម្រូវការកម្លាំងពលកម្មនាពេលអនាគត ដោយសារការចូលមកជំនួសរបស់បច្ចេកវិទ្យាវៃឆ្លាត ដូចជា រ៉ូបូត និងបញ្ញាសិប្បនិម្មិតជាដើម។

## តើបច្ចេកវិទ្យាវៃឆ្លាតពិតជាចូលមកជំនួសកម្លាំងពលកម្មមនុស្សទាំងស្រុងមែនឬទេ?

ជាការពិតណាស់ បច្ចេកវិទ្យាពិតជាបានចូលរួមជួយសម្រួលដល់កម្លាំងមនុស្ស និងធ្វើឱ្យការងារកាន់តែមានភាពរហ័ស និងទទួលបានប្រសិទ្ធភាពខ្ពស់ជាងមុន ប៉ុន្តែមិនមែនមានន័យថាបច្ចេកវិទ្យានឹងចូលមកជំនួសឱ្យកម្លាំងពលកម្មមនុស្សបានទាំងស្រុងនោះទេ ដោយយោងតាមទឡ្ហីករណ៍មួយចំនួនដូចខាងក្រោម៖

### ១. បច្ចេកវិទ្យានឹងសហការជាមួយមនុស្ស ជាជាងជំនួសកម្លាំងមនុស្ស

រ៉ូបូត ឬ AI នឹងមិនទៅជំនួសកម្លាំងមនុស្សនោះទេប៉ុន្តែវានឹងសហការជាមួយមនុស្ស តាមរយៈការជំរុញផលិតភាពរបស់ផលិតកម្មឱ្យកាន់តែប្រសើរជាងមុនមានប្រសិទ្ធភាពជាងមុន និងអាចធ្វើការសម្រេចចិត្តនៅពេលវេលាជាក់ស្តែងបានល្អជាងមុន។ ឧទាហរណ៍៖ កាលពីអតីតកាល អ្នកធ្វើការផ្នែកបកប្រែប្រើប្រាស់វចនានុក្រមសៀវភៅសម្រាប់បកប្រែពាក្យ។ ងាកមកមើលនាពេលបច្ចុប្បន្នវិញ នៅក្នុងយុគសម័យឌីជីថលនេះ បច្ចេកវិទ្យាកាន់តែមានការរីកចម្រើនខ្លាំងឡើងៗ ដោយមនុស្សប្រើប្រាស់វចនានុក្រមអេឡិចត្រូនិក, អ៊ីនធឺណិត ឬ បច្ចេកវិទ្យា AI ដែលអាចជួយសម្រួលដល់ការងាររបស់ពួកគេឱ្យកាន់តែងាយស្រួល, មានប្រសិទ្ធភាពខ្ពស់ និងចំណេញពេលវេលាជាងមុន។ យើងសង្កេតឃើញថា ថ្វីត្បិតតែបច្ចេកវិទ្យាត្រូវបានប្រើនៅក្នុងការងារនេះក៏ពិតមែន តែបច្ចេកវិទ្យាតែឯងមិនអាចធ្វើការងារនេះបានដោយគ្មានមនុស្សនោះទេ ដែលចាំបាច់នៅតែត្រូវការមនុស្សដែលចេះប្រើប្រាស់បច្ចេកវិទ្យានេះ។

### ២. ការងារមានភាពបត់បែនជាងមុន

ជំនួយការឌីជីថល AI–ngels ដែលគ្រប់គ្រងដោយ AI នឹងគ្រប់គ្រងទិន្នន័យផ្ទាល់ខ្លួន និងទិន្នន័យនៅកន្លែងធ្វើការ ដែលអាចជួយមនុស្សក្នុងការចាត់ចែងលំដាប់ការងារដែលត្រូវធ្វើមុន និងការងារដែលត្រូវធ្វើបន្តបន្ទាប់។ លើសពីនេះទៅទៀត បច្ចេកវិទ្យានេះនឹងជួយសម្រួលដល់លក្ខខណ្ឌការងាររបស់ពួកគេ ដែលអនុញ្ញាតឱ្យពួកគេអាចធ្វើការងារបាននៅគ្រប់ពេលវេលា និងនៅគ្រប់ទីកន្លែង។

### ៣. មានតែមនុស្សប៉ុណ្ណោះដែលអាចធ្វើការងារដែលមានភាពបត់បែន និងគ្មានលក្ខណៈដដែលៗបាន (Non–standardized tasks)

ស្របពេលដែលស្វ័យប្រវត្តិកម្មត្រូវបានប្រើប្រាស់នៅក្នុងវិស័យការងារ គេសង្កេតឃើញថា ការងារមួយចំនួនធំគឺ មិនបានបាត់បង់ ឬជំនួសដោយបច្ចេកវិទ្យានោះទេ តួយ៉ាងរ៉ូបូត ឬ AI ត្រូវបានប្រើប្រាស់សម្រាប់តែការងារដែលមានលក្ខណៈដដែលៗប៉ុណ្ណោះ។ ឧទាហរណ៍៖ សម្រាប់ការជ្រើសរើសបុគ្គលិក AI នឹង

ជួយសម្រួលក្នុងការសម្រាំងយកបុគ្គលិកដែលស្របទៅតាមតម្រូវការ (shortlist) បន្ទាប់មកមនុស្សនឹងធ្វើការងារនៅដំណាក់កាលបន្តបន្ទាប់ទៀត ដែលការងារទាំងនោះ AI មិនអាចធ្វើជំនួសបាន។ នៅក្នុងវិស័យសុខាភិបាល AI អាចមើលពីអាការៈអ្នកជំងឺ វិភាគអំពីរោគសញ្ញា និងធ្វើរោគវិនិច្ឆ័យ ប៉ុន្តែមានតែមនុស្សប៉ុណ្ណោះដែលអាចមើលអំពីទឹកមុខ និងស្ថានភាពជាក់ស្តែងរបស់អ្នកជំងឺ ក៏ដូចជាដឹងអំពីវិធីសាស្ត្រក្នុងការបកស្រាយប្រាប់អ្នកជំងឺ។

## ៤. <u>បច្ចេកវិទ្យានឹងធ្វើឱ្យជំនាញរបស់មនុស្សកាន់តែសំខាន់</u>

មនុស្សនឹងប្រើប្រាស់បច្ចេកវិទ្យាដើម្បីសម្រួលដល់ការងារជំនាញរបស់ពួកគេ ដែលអាចធ្វើឱ្យការងារកាន់តែមានភាពរលូនជាងមុន ខណៈពេលដែលគ្មានបច្ចេកវិទ្យាវៃឆ្លាតណាអាចធ្វើជំនួសមនុស្សបាននោះទេ។ ឧទាហរណ៍៖ ការប្រើប្រាស់បច្ចេកវិទ្យារបស់គ្រូបង្រៀនសម្រាប់ការបង្រៀន បានជួយសម្រួលដល់ការបង្រៀន ទោះបីជាមិនអាចបង្រៀននៅទីតាំងផ្ទាល់ និងអាចជួយសម្រួលដល់ការសិក្សារបស់សិស្ស។ គ្រូបង្រៀនក៏អាចធ្វើការថតវីដេអូបង្រៀនទុកផងដែរ ដែលអនុញ្ញាតឱ្យសិស្សអាចមើលការបង្រៀនឡើងវិញដោយខ្លួនឯង ឬសម្រាប់សិស្សដែលមិនបានមករៀន។

## ៥. <u>បច្ចេកវិទ្យានឹងបង្កើតការងារថ្មីៗ</u>

ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យា ប្រភេទការងារថ្មីៗនឹងត្រូវបានបង្កើតឡើង សម្រាប់ចូលរួមគាំទ្រដល់សកម្មភាពផ្សេងៗនៅក្នុងយុគសម័យឌីជីថល។ ឧទាហរណ៍៖ កាលពីអតីតកាល ការងារនៅក្នុងវិស័យឌីជីថល ដូចជា ទីផ្សារឌីជីថលគឺមិនមាននោះទេ។ នៅពេលដែលមានការរីកចម្រើននៃបច្ចេកវិទ្យា ការងារនៅក្នុងវិស័យឌីជីថលបានកើតមានឡើងជាមួយនឹងសន្ទុះកើនឡើងខ្លាំង ហើយកំពុងមានតម្រូវការខ្លាំងទៀតផង។ លើសពីនេះទៀត ស្របពេលដែលបច្ចេកវិទ្យាមានការរីកចម្រើន មនុស្សបានចាប់ផ្តើមបញ្ជាទិញទំនិញពីចំងាយ ដែលធ្វើឱ្យលេចចេញនូវតម្រូវការកម្លាំងពលកម្មផ្នែកដឹកជញ្ជូន ថែមទៀតផង។

សរុបមក បច្ចេកវិទ្យានឹងមិនទៅជំនួសកម្លាំងពលកម្មមនុស្សទាំងស្រុងនោះទេ ដោយមនុស្សនឹងមិនបាត់បង់ការងារដោយសារការរីកចម្រើននៃបច្ចេកវិទ្យានោះឡើយ។ ផ្ទុយទៅវិញ បច្ចេកវិទ្យានឹងជួយសម្រួលដល់ការងាររបស់មនុស្ស ក៏ដូចជាបង្កើតប្រភេទការងារថ្មីៗបន្ថែមទៀតសម្រាប់កម្លាំងពលកម្ម។ ស្របពេលដែលការរីកចម្រើននៃបច្ចេកវិទ្យាគឺជានិន្នាការសកលដែលមិនអាចចៀសផុត កម្លាំងពលកម្មចាំបាច់ត្រូវពង្រឹងសមត្ថភាព ចំណេះ និងជំនាញផ្នែកឌីជីថល ពោលគឺមនុស្ស និងបច្ចេកវិទ្យាត្រូវដើរទន្ទឹមគ្នា ដើម្បីអាចធានាបានថាធនធានមនុស្សមានសមត្ថភាពគ្រប់គ្រាន់អាចដើរទាន់ ប្រើប្រាស់ និងទាញប្រយោជន៍ពីការរីកលូតលាស់នៃបច្ចេកវិទ្យាបាន៕

## ឯកសារយោង


- *AI won't replace humans, just like computers didn't by Iain Brown, IET sites*
- *Robots will not replace humans but they will make us smarter and more efficient by Aditi Sharma Kalra, Human Resources*
- *Why AI won't replace Humans? Kalyani Kolli*
- *Why machines will not replace us? by Danny Goh, Terence Tse and Mark Esposito, The Decision Lab*
- *Collaborative Intelligence: Humans and AI Are Joining Forces, Harvard Business Review*


---


កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

www.cambodia4point0.org

cambodia_4.0

cambodia4point0